# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ការបង្ហាត់បង្រៀនអំពីប្រល័យពូជសាសន៍ ៖ គម្រោងស្ដីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**
**វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ជាតិស្ដីពីការបង្រៀនប្រវត្តិសាស្ត្រ**
**កម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា**

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា


## ការអភិវឌ្ឍខាងចំណេះដឹង


**ជីន ផាយគេត**


ផាយគេត ត្រូវបានកំណត់ថាជាអ្នកស្ថាបនានិយម និងជាអ្នកធ្វើអន្តរកម្ម ។ ការចាប់អារម្មណ៍របស់គាត់ចំពោះការអភិវឌ្ឍខាងចំណេះដឹងចេញមកពីការចាប់អារម្មណ៍របស់គាត់ទៅលើប្រភពនៃការយល់ដឹង និងការបណ្ដុះបណ្ដាលខាងវិទ្យាសាស្ត្រធម្មជាតិ ។ ផាយគេតមានការចាប់អារម្មណ៍ស្ដីអំពីថាតើក្មេងចាប់ផ្ដើមយល់និងស្គាល់ពិភពលោកយ៉ាងដូចម្ដេច ។ គាត់បានបង្កើតទ្រឹស្ដីចំណេះដឹងនេះ តាមរយៈការអង្កេត និងការសិក្សារបស់ក្មេង (ដែលក្មេងមួយចំនួនជាកូនរបស់ខ្លួនដែរ) ។ ការប្រើប្រាស់សំណួរមួយចំនួនធ្វើជាចំណុចចាប់ផ្ដើម គាត់ធ្វើតាមការគិតរបស់ក្មេង ហើយទុកឲ្យសំណួរនោះ មានលក្ខណៈបត់បែនបាន ។ ផាយគេត ជឿជាក់ថា ការនិយាយដោយឯកឯង ឬអត់ព្រាងទុករបស់ក្មេង បានផ្ដល់នូវតម្រុយដ៏មានអត្ថប្រយោជន៍ក្នុងការយល់អំពីការគិតរបស់ក្មេង ។ គាត់មិនចាប់អារម្មណ៍ថាជាចម្លើយខុសឬត្រូវទេ ជាជាងការគិតបែបសមហេតុផលដែលក្មេងប្រើប្រាស់ ។

បន្ទាប់ពីបានសង្កេតមើលជាច្រើនឆ្នាំមក ផាយគេតបានសន្និដ្ឋានថា ការអភិវឌ្ឍខាងចំណេះដឹងជាលទ្ធផលនៃប្រតិកម្មតបតគ្នាពីកំណើត និងដោយសារកត្តាបរិស្ថាន ។ ដោយសារក្មេងៗបានអភិវឌ្ឍនិងប្រតិកម្មតបតជាប្រចាំជាមួយនឹងពិភពជុំវិញខ្លួន ចំណេះដឹងត្រូវបានបង្កើត និងបង្កើតឡើងសាជាថ្មីព្រមទាំងវិវឌ្ឍន៍តាមពេលវេលា ។ ទ្រឹស្ដីអភិវឌ្ឍខាងចំណេះដឹងរបស់ ផាយគេត ត្រូវបានបង្កើតឡើងនៅក្នុងវិទ្យាសាស្ត្រជីវសាស្ត្រ ។ គាត់បានចាត់ទុកការរីកចម្រើនខាងចំណេះដឹងថាជាការពង្រីកការរីកចម្រើនខាងកត្តាជីវសាស្ត្រ ដែលគ្រប់គ្រងរាល់ទិដ្ឋភាពផ្សេងៗទៀត ផ្នែកខាងការអភិវឌ្ឍផ្លូវអារម្មណ៍ សង្គម និងសីលធម៌ ។

### ដំណាក់កាលនៃការអភិវឌ្ឍខាងចំណេះដឹង

ផាយគេត យល់ឃើញថា ក្មេង បានគិត និងផ្តល់ហេតុផលខុសៗគ្នាក្នុងរយៈពេលខុសៗគ្នានៅក្នុងជីវិតរបស់ខ្លួន ។ គាត់ជឿថាមនុស្សម្នាក់ៗជួបប្រទះហេតុការណ៍ជាបន្តបន្ទាប់គ្នាមានបួនដំណាក់-កាលខុសៗគ្នា ។ បើទោះជាក្មេងធម្មតាម្នាក់ៗបានឆ្លងកាត់ដំណាក់កាលតាមលំដាប់លំដោយដូចគ្នាក៏ដោយ ក៏មានភាពខុសប្លែកគ្នាតាមវ័យ ដែលក្មេងទទួលបានតាមដំណាក់កាលនីមួយៗដែរ ។ ដំណាក់-កាលអភិវឌ្ឍន៍ខាងចំណេះដឹងចំនួន៤របស់ ផាយគេត គឺ ៖

| ដំណាក់កាល | អាយុ | កិច្ចការខាងចំណេះដឹង |
|---|---|---|
| ការយល់ដឹងខាងវិញ្ញាណ | ពីថ្ងៃកំណើតដល់អាយុ២ឆ្នាំ | ការរៀនតាមវត្ថុជាក់ស្តែង |
| ប្រតិបត្តិការមុន | អាយុ២ ដល់ ៧ឆ្នាំ | ការរៀនតាមនិមិត្តរូប |
| ប្រតិបត្តិការជាក់ស្តែង | អាយុ៧ ដល់១១ ឆ្នាំ | ការរៀននៅក្នុងថ្នាក់ ទំនាក់ទំនង និងទូរលេខ<br>និងចេះរបៀបឲ្យហេតុផល |
| ប្រតិបត្តិការផ្លូវការ<br>(ការគិតអំពីអរូបិយ) | អាយុ១១ឆ្នាំឡើង | ការរៀនគិត (អេវ៉ាន ១៩៧៣) |

ដំណាក់កាលអភិវឌ្ឍន៍ចំណេះដឹង ដែល ផាយគេត បានរកឃើញ មានជាប់ទាក់ទងជាមួយនឹងវ័យ និងចរិតលក្ខណៈរបស់ក្មេង ។ បើយោងតាម ផាយគេត ដំណាក់កាលនីមួយៗមានទម្រង់លម្អិតជាច្រើន ។ ឧទាហរណ៍ ដំណាក់កាលប្រតិបត្តិការជាក់ស្តែងមានរចនាសម្ព័ន្ធជាង៤០ខុសៗគ្នា ដោយគ្របដណ្តប់ទៅលើចំណាត់ថ្នាក់ និងទំនាក់ទំនង ពេលវេលា ឱកាស ចលនា ចំនួន និងវាស់ស្ទង់ ។

រចនាសម្ព័ន្ធខាងចំណេះដឹងផ្លាស់ប្តូរតាមរយៈដំណើរការនៃកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលជាប្រចាំៈ ការបញ្ច្រាប និងការសម្រួល ។

| |
|---|
| **ការបញ្ច្រាប**<br>ជាប់ពាក់ព័ន្ធទៅនឹងការបកស្រាយហេតុការណ៍ទាក់ទងទៅនឹងរចនាសម្ព័ន្ធចំណេះដឹងមានស្រាប់ ។ |
| **ការសម្រួល** សំដៅលើការផ្លាស់ប្តូររចនាសម្ព័ន្ធចំណេះដឹង ដែលនាំឲ្យស្គាល់នូវបរិស្ថាន ។ |

| ឧទាហរណ៍ | គោលការណ៍ |
|---|---|
| នៅក្នុងដំណាក់កាលយល់ដឹងខាងវិញ្ញាណ គ្រូគួរតែ | ១. ក្មេងនឹងផ្តល់ការពន្យល់ខុសៗគ្នាអំពីការពិត |

| | |
|---|---|
| ព្យាយាមផ្តល់នូវបរិស្ថានដ៏សម្បូរបែប និងមានកម្លាំងជំរុញ នូវវត្ថុគំរូសម្រាប់សិស្សលេង<br><br>នៅក្នុងដំណាក់កាលប្រតិបត្តការជាក់ស្តែង គ្រូគួរតែផ្តល់សកម្មភាពរៀនសូត្រ ដែលជាប់ពាក់ព័ន្ធនឹងបញ្ហាកំណត់ចំណាត់ថ្នាក់ បញ្ជារ ទីតាំង ការអភិរក្ស ដោយប្រើប្រាស់វត្ថុជាក់ស្តែង | នៅក្នុងដំណាក់កាលផ្សេងៗគ្នា ចំពោះការអភិវឌ្ឍន៍ខាងចំណេះដឹង<br>២. ការអភិវឌ្ឍត្រូវបានសម្របសម្រួល តាមរយៈការផ្តល់សកម្មភាព ឬសភាពការណ៍ ដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នករៀន និងតម្រូវឲ្យមានការសម្របសម្រួល (ការបញ្ច្រាប និងការសម្របសម្រួល) ។<br>៣. ការរៀនអំពីវត្ថុ និងសកម្មភាព គួរតែជាក់ពាក់ព័ន្ធទៅនឹងកម្រិតប្រតិបត្តិការតាមសតិអារម្មណ៍ចំពោះក្មេងតាមវ័យ ចៀសវាងសុំឲ្យសិស្សបំពេញភារកិច្ច ដែលហួសពីសមត្ថភាពខាងចំណេះដឹង ។<br>៤. ប្រើប្រាស់វិធីសាស្ត្របង្រៀន ដែលជាប់ពាក់ព័ន្ធទៅនឹងសិស្ស និងការប្រឈមមុខនាពេលបច្ចុប្បន្ន ។ |

## ការជាប់ព័ន្ធជាមួយការអប់រំ

គរុកោសល្យអប់រំរបស់ ជាយគេត បានគូសបញ្ជាក់អំពីទស្សនៈវិស័យខាងការអប់រំដែលផ្តោតសំខាន់លើអ្នករៀន ។ អាស្រ័យហេតុនេះហើយ កម្មវិធីសិក្សា និងបទពិសោធន៍នៃការរៀន គួរតែមានគម្រោងអនុញ្ញាតឲ្យមានឱកាសក្នុងការបញ្ច្រាប និងសម្របសម្រួល ។ សិស្ស ត្រូវតែរកឲ្យឃើញ ជួបប្រទះ កែប្រែ ចោទសួរ និងរកចម្លើយខ្លួនឯង-សកម្មភាពមានលក្ខណៈសំខាន់ ។ តែទោះជាយ៉ាងណាប្រការនេះមិនមានន័យថា ក្មេងៗគួរតែអនុញ្ញាតឲ្យធ្វើអ្វីតាមដែលខ្លួនចង់នោះទេ ។

ដូច្នេះ តើគ្រូមានតួនាទីបែបណា? គ្រូគួរតែមានលទ្ធភាពវាយតម្លៃទៅលើកម្រិតចំណេះដឹងនាពេលបច្ចុប្បន្នរបស់សិស្ស ចំណុចខ្លាំង និងចំណុចខ្សោយ ។ សេចក្តីណែនាំគួរតែធ្វើឡើងតាមបុគ្គលម្នាក់ៗ ហើយសិស្សគួរតែមានឱកាសទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីពិភាក្សា និងនិយាយអំពីបញ្ហានេះ ។ គ្រូគួរតែមានតួនាទីជាអ្នកសម្របសម្រួលខាងចំណេះដឹង-គ្រូជាអ្នកនាំផ្លូវ និងជួយជំរុញសិស្ស ។

គ្រូ គួរតែអនុញ្ញាតឲ្យសិស្សធ្វើឲ្យមានកំហុស ហើយរៀនពីកំហុសនោះ។ ការរៀនគឺមានអត្ថន័យយ៉ាងខ្លាំង ប្រសិនសិស្សត្រូវបានអនុញ្ញាតឲ្យជួបប្រទះ ជាជាងស្តាប់គ្រូបង្រៀនសុទ្ធសាធ។ គ្រូគួរតែបង្ហាញសិស្សនូវសម្ភារៈ និងសកម្មភាព ដែលអនុញ្ញាតឲ្យសិស្សទាំងអស់ស្វែងយល់នូវការរៀនបែបថ្មី។